**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

Logo
រដ្ឋបាលរាជធានី
ខេត្ត

លេខ...................

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតក្រុមការងារគណនេយ្យភាពសង្គមថ្នាក់រាជធានី ខេត្ត

**អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១/៩២៥ ចុះថ្ងៃទី០៦ ខែ កញ្ញា ឆ្នាំ២០១៨ ស្ដីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែល ប្រកាសឱ្យប្រើច្បាប់ ស្ដីពីគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០១៥ ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ២០០១ ដែល ប្រកាសឱ្យប្រើច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និង ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យ លេខ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និង រចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យ លេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និង រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ នៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យ លេខ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និង រចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៩៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែ ធ្នូ ឆ្នាំ២០១៩ ស្ដីពីការប្រគល់ មុខងារ គ្រប់គ្រង និងការផ្ដល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត
- យោងលិខិតលេខ៥២៩ ល.ស/គ.ជ.អ.ប ចុះថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ២០១៦ របស់គណៈ កម្មាធិការជាតិសម្រាប់អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
- យោងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងផែនការអនុវត្តបីឆ្នាំដំណាក់កាលទី៣ (២០១៨-២០២០) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ចុះថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ២០១៧

- យោងផែនការយុទ្ធសាស្ត្រ ស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចុះថ្ងៃទី១១ ខែ កក្កដា ឆ្នាំ២០១៣
- យោងផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្នាំ ២០១៦-២០១៨ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០១៦
- យោងផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០១៩-២០២៣) ចុះថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ២០១៩។
- យោងតាមការចាំបាច់របស់រដ្ឋបាលរាជធានី ខេត្ត

## សម្រេច

**ប្រការ ១.**_

ត្រូវបានបង្កើតក្រុមការងារគណនេយ្យភាពសង្គមថ្នាក់រាជធានី ខេត្តដូចខាងក្រោមៈ

| | |
|---|---|
| ១-ឯកឧត្តម លោកជំទាវអភិបាលរង នៃគណៈអភិបាលរាជធានី ខេត្ត | ជាប្រធាន |
| ២-លោក លោកស្រី នាយក ឬនាយករងរដ្ឋបាលរាជធានី ខេត្ត | អនុប្រធាន |
| ៣-លោក លោកស្រី ប្រធាន ឬអនុប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត | សមាជិក |
| ៤-លោក លោកស្រី ប្រធាន ឬអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត | សមាជិក |
| ៥-លោក លោកស្រី ប្រធាន ឬអនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត | សមាជិក |
| ៦-លោក លោកស្រី ប្រធាន ឬអនុប្រធានរតនាគាររាជធានី ខេត្ត | សមាជិក |
| ៧-លោក លោកស្រី នាយកទីចាត់ការផែនការនិងវិនិយោគរាជធានី ខេត្ត | សមាជិក |
| ៨-លោក លោកស្រី នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្សរាជធានី ខេត្ត | សមាជិក |
| ៩-លោក លោកស្រី នាយកទីចាត់ការអន្តរវិស័យរាជធានី ខេត្ត | សមាជិក |
| ១០-លោក លោកស្រី នាយកទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្ត | សមាជិក |
| ១១-លោក លោកស្រី ប្រធានការិយាល័យកសាងសមត្ថភាពរាជធានី ខេត្ត | សមាជិក |
| ១២-លោក លោកស្រី ប្រធានការិយាល័យគាំទ្រមូលដ្ឋានរាជធានី ខេត្ត | សមាជិក |
| ១៣-លោក លោកស្រី ប្រធានការិយាល័យវិនិយោគរាជធានី ខេត្ត | សមាជិក |
| ១៤-លោក លោកស្រី មន្ត្រីបង្គោលគណនេយ្យភាពសង្គមរាជធានី ខេត្ត | សមាជិកអចិន្ត្រៃយ៍ |
| ១៥-លោក លោកស្រី អភិបាលក្រុង ស្រុក ខណ្ឌគោលដៅ | សមាជិក |
| ១៦-តំណាងអង្គការមិនមែនរដ្ឋាភិបាល ដៃគូអនុវត្តការងារគណនេយ្យភាពសង្គម | សមាជិក |

**ប្រការ ២.**_

**ក្រុមការងារគណនេយ្យភាពសង្គមថ្នាក់រាជធានី ខេត្ត មានតួនាទីភារកិច្ចដូចខាងក្រោមៈ**

- គាំទ្ររដ្ឋបាលរាជធានី ខេត្តក្នុងការអភិវឌ្ឍសមត្ថភាពពាក់ព័ន្ធនឹងការ អនុវត្តការងារគណនេយ្យភាពសង្គមដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីបង្គោលគណនេយ្យភាពសង្គមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ស្ថាប័នពាក់ព័ន្ធ (មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត មន្ទីរសុខាភិបាលរាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ)

លេខាធិការដ្ឋាន

- គាំទ្រការអនុវត្តទាំងផ្នែកផ្គត់ផ្គង់(តួអង្គរដ្ឋ) និងផ្នែកតម្រូវការ ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល តាមគោលការណ៍នានា នៃផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- សម្របសម្រួលការងារទូទៅជាមួយស្ថាប័ន មន្ទីរ អង្គភាព និងអង្គការដៃគូអនុវត្តនៅមូលដ្ឋាន
- គាំទ្រការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់ការងារគណនេយ្យភាពសង្គម
- រៀបចំរបាយការណ៍ជាប្រចាំជូនថ្នាក់ដឹកនាំ និងរៀបចំរបាយការណ៍ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីវឌ្ឍភាព និងបញ្ហាប្រឈមនានាការអនុវត្តការងារគណនេយ្យភាពសង្គមជូនថ្នាក់ដឹកនាំសម្រាប់រាយការណ៍ និងក្នុងកិច្ចប្រជុំក្រុមប្រឹក្សានៅក្នុងពេលអនុវត្ត ព្រមទាំងសម្របសម្រួល រវាងផ្នែកផ្គត់ផ្គង់ និង ផ្នែកតម្រូវការ
- រៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម ជូនលេខាធិការដ្ឋាន គ.ជ.អ.ប
- តាមដាន ត្រួតពិនិត្យ និងចូលរួមក្នុងការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម នៅក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- រៀបចំប្រជុំទៀងទាត់នូវរាល់ត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម
- អនុវត្តតួនាទីភារកិច្ចផ្សេងៗទៀត ពាក់ព័ន្ធនិងការងារគណនេយ្យភាពសង្គម ដែលថ្នាក់ដឹកនាំប្រគល់ជូន

**ប្រការ ៣._**

អភិបាលរង នាយក ឬនាយករងរដ្ឋបាលរាជធានី ខេត្ត ប្រធានមន្ទីរ អង្គភាពជំនាញ នាយកទីចាត់ការ និងប្រធានអង្គភាពចំណុះសាលាខេត្ត អភិបាលក្រុង ស្រុក ខណ្ឌ និងឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ......................ខែ......... ឆ្នាំ................. ព.ស.២៥៦......

..................ថ្ងៃទី ខែ ឆ្នាំ២០២

**អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**ចម្លងជូន៖**

-ក្រសួងស្ថាប័នពាក់ព័ន្ធ
-លេខាធិការដ្ឋាន គ.ជ.អ.ប
-មន្ទីរពាក់ព័ន្ធ
-អង្គការសង្គមស៊ីវិល ដៃគូអនុវត្ត
"ដើម្បីជូនជ្រាប"
-ប្រការ១ និងប្រការ៣
"ដើម្បីសហការអនុវត្ត"
-ឯកសារ កាលប្បវត្តិ